# មនុស្សឆ្លាតពីរប្រភេទ

## ប្រភេទទី ១ មនុស្សឆ្លាតតែធ្វើជាល្ងង់

## ប្រភេទទី ២ មនុស្សឆ្លាតហើយអួត



Shared By Facebook Page: Sokha Kimly




តាមធម្មតា បើនិយាយពីមនុស្សឆ្លាត យើងនឹងនឹកដល់ការប្រព្រឹត្តខុសប្លែកពីអ្នកដទៃរបស់ពួកគេ តែយើងក៏អាចបែងចែកជាពីរប្រភេទ ៖

ប្រភេទទី១ គឺ មនុស្សឆ្លាតតែធ្វើជាល្ងង់

ប្រភេទទី២ គឺ មនុស្សឆ្លាតហើយអួត ។

① ប្រភេទទី១ គឺ មនុស្សឆ្លាតតែធ្វើជាល្ងង់ ដែលជាមនុស្សកម្ររកណាស់។ មនុស្សប្រភេទនេះ ចូលចិត្តធ្វើជាមឹះៗ ស្លូតបូត តែការពិតគឺគេលាក់ភាពឆ្លាតទុក ហើយដឹងគ្រប់បែបហើយ គ្រាន់តែគេមិនបញ្ចេញ ឬរង់ចាំឱកាសសមរម្យ ទើបបញ្ចេញជាតុពិតរបស់គេប៉ុណ្ណោះមនុស្សប្រភេទនេះ ចេះធ្វើឲ្យខ្លួនមានតម្លៃ ចេះកំណត់គោលដៅខ្ពស់ តែបែរជានៅកន្ទែងទាប ធ្វើខ្លួនឲ្យចូលគ្រប់ស្ថានការណ៍ មិនធ្វើអ្វីឲ្យលេចធ្លោគ្រប់ពេល។ យើងមានពាក្យមួយឃ្លាដើម្បីឲ្យនិយមន័យ

ប្រភេទនេះ គឺ ដើរផាប់ដី ដែលចាប់ផ្ដាយ។ នៅក្នុងរឿងសាមកុក យើងអាចមើលឃើញមនុស្សឆ្លាតប្រភេទទី២ជាច្រើនដូចជា យ៉ាងសៀវ ដែលពូកែទាយចិត្តរបស់ឆាវឆាវ។ ការទាយរបស់យ៉ាងសៀវ ត្រឹមត្រូវសូម្បីតែឆាវឆាវ ក៏ភ្ញាក់ផ្អើលនឹងប្រាជ្ញារបស់គេដែរ។ តែទីបំផុតភាពឆ្លាតនេះ ក្លាយជាគ្រោះដល់ជីវិតរបស់គាត់ទៅវិញ ។ អ្នកដែលបានមើលរឿង ប្រាកដជានៅចាំវគ្គ ទ្រូងមាន់ហើយ ។

ស្លាប់ដោយសារប្រាជ្ញា ទោះឆ្លាតប៉ុណ្ណាក៏គេថាល្ងង់ដែរ។ យ៉ាងសៀវ ចង់អួតខ្លួនថាជាមនុស្សឆ្លាត ទាយគំនិតឆាវឆាវនៅមុខអ្នកដទៃរហូត ដែលនេះក៏ធ្វើឲ្យឆាវឆាវមិនពេញចិត្តដែរ។ ចំណែកមនុស្សប្រភេទទី១វិញ ចៀសមិនផុត ពីស៊ឺម៉ាអ៊ីនិងឆាវភីទេ ។ ពីរនាក់លាក់ភាពឆ្លាតទុករហូត បើឆាវភីវិញធ្វើខ្លួនជាល្ងង់តែតាមពិតរៀបចំផែនការគ្រប់សព្វ សូម្បីតែក្នុងវេទិកាក្លោកស្លាន់ ក៏ឆាវភី រៀបចំអត្ថបទកំណាព្យពីរផ្សេងគ្នាដែរ។ ស៊ឺម៉ាអ៊ី ពូកែដាក់ខ្លួន មិនបញ្ចេញភាពឆ្លាតក្នុងពេលមិនសមរម្យ។

និយាយឲ្យខ្លី ការមានភាពឆ្លាតជារឿងល្អ តែគេមិនយកមកប្រើពាសវាលពាសកាលទេ ព្រោះភាពឆ្លាតប្រៀបដូចជាកាំបិតដែលមានមុខពីរ អាចផ្ដល់ប្រយោជន៍ក៏អាចនាំទុក្ខដាក់ខ្លួនដែរ។ ការរៀនមើលឱកាសថាសមរម្យឬអត់ ជារឿងសំខាន់សម្រាប់មនុស្សទូទៅ។ បើសិនជាស្គាល់ឱកាស សុទ្ធតែអាចចាត់ទុកជាមនុស្សឆ្លាតបានហើយ។ អត្ថបទនេះខ្ញុំយកគោលគំនិតក្នុងសៀវភៅមកសរសេរទេ គ្រាន់តែខ្ញុំប្រើឧទាហរណ៍ផ្ទាល់ខ្លួនប៉ុណ្ណោះ។




② ប្រភេទទី២ គឺ មនុស្សឆ្លាតហើយអួត។ មនុស្សប្រភេទនេះ មានមិនតិចទេ។ សូមកុំច្រលំនឹងមនុស្សល្ងង់ដែលអួតខ្លួនឆ្លាត។ មនុស្សឆ្លាតប្រភេទនេះចូលចិត្តប្រកាសខ្លួនថា មានភាពឆ្លាតពូកែអស្ចារ្យ ហើយមើលងាយអ្នកដទៃថាជាមនុស្សល្ងង់។ មនុស្សប្រភេទនេះ មិនសូវមានគេរាប់អានច្រើនទេ ព្រោះច្រើនតែធ្វើឲ្យអ្នកដទៃអន់ចិត្តជានិច្ច ឬខឹងសម្បារដោយសារពាក្យសម្តី ឬកាយវិការរបស់ពួកគេ ។ហើយប្រសិនជាបើមានគេរាប់អានវិញក៏គេរាប់អានដើម្បីតែយកផលប្រយោជន៍ពីភាពឆ្លាតប៉ុណ្ណោះ។

ខ្ញុំសង្ឃឹមថា អ្នករាល់គ្នានឹងរើសយកមនុស្សឆ្លាតប្រភេទទី១ ក្រោយពីអានអត្ថបទនេះរួច។ ខ្ញុំមានសំណូមពរមួយគឺ សូមកុំឲ្យពាក្យលាក់ពុត និងពាក្យស្មោះត្រង់ក្លាយជាចំណងចងជើងយើងឲ្យធ្វើជាមនុស្សប្រភេទទី២ ។ តើមានអ្នកណាយល់ឃើញខុសពីនេះទេ?